**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

# សេចក្តីថ្លែងការណ៍
# របស់អ្នកនាំពាក្យក្រសួងមហាផ្ទៃ

កាលពីព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ វិទ្យុអាស៊ីសេរីបានចាក់ផ្សាយបទសម្ភាសន៍ជាមួយ លោក ប្រេដ អាដាម នាយកប្រតិបត្តិអង្គការសិទ្ធិមនុស្ស Human Rights Watch ប្រចាំនៅតំបន់អាស៊ី ដោយ បានលើកឡើងអំពីស្ថានភាព ឃុំឃាំង និងការរស់នៅរបស់អតីតមេដឹកនាំខ្មែរក្រហមនៅក្នុងមណ្ឌលឃុំឃាំង ព្រមទាំងបាន ធ្វើការប្រៀបធៀបទៅនឹងស្ថានភាពរស់នៅ របស់ប្រជាពលរដ្ឋកម្ពុជា ។ ធ្ងន់ធ្ងរជាងនេះទៅទៀតលោក ប្រេដ អាដាម បានប្រើពាក្យអសុរស ដោយបានប្រៀបប្រដូចស្ថានភាពរស់នៅរបស់អ្នកទោសនៅក្នុង ពន្ធនាគារកម្ពុជាទៅនឹងការរស់នៅរបស់សត្វឆ្កែ។

អ្នកនាំពាក្យក្រសួងមហាផ្ទៃចាត់ទុកថា ទស្សនៈខាងលើនេះ គឺជាការវាយតំលៃដោយភាពអគតិ ភាពជាអ្នក ដែលមានគំនុំគំគួនជាបុគ្គល ហើយនោះគឺជាការមើលស្រាលចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា ក្រសួងមហាផ្ទៃ ព្រមទាំងដៃគូអភិវឌ្ឍន៍មួយចំនួន ដែលបានផ្តល់ធនធានក្នុងការជួយវិនិយោគធ្វើឱ្យ ប្រសើរឡើងនូវវិស័យ ពន្ធនាគារនៅកម្ពុជា។

ក្រសួងមហាផ្ទៃសូមធ្វើការបំភ្លឺជូនមតិសាធារណៈជាតិ និងអន្តរជាតិដូចខាងក្រោម ៖

**១**.យើងទទួលស្គាល់ដូចលោក ប្រេដ អាដាម ដែរថា ការរៀបចំកាត់ទោសលើជនសង្ស័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺជាការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ។ ដូចនេះជនទាំងនោះគួរត្រូវ ទទួលបាននូវសេវាគ្រប់គ្រង តាមបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងអ្នកទោស យ៉ាង ពេញលេញ មិនថានៅកម្ពុជា ឬក៏នៅប្រទេសណាទេ ដូច្នេះមិនចាំបាច់ប្រៀបធៀបស្ថានភាពនេះ ទៅនឹងជីវភាពរស់ នៅរបស់ប្រជាជនសាមញ្ញ ឬស្ថានភាពរស់នៅក្នុងពន្ធនាគារ កម្ពុជាឡើយ ។

**២**.លោក ប្រេដ អាដាម ត្រូវពិចារណាឱ្យបានស៊ីជំរៅថែមទៀតថា បទដ្ឋានអប្បរមារបស់អង្គការ-សហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោសគឺមិនអាចយកទៅអនុវត្តឱ្យបានដូចៗគ្នានៅគ្រប់ពន្ធនាគារទូទាំងពិភពលោកបានទេ គឺវាអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗ ដូច្នេះពន្ធនាគារនៅកម្ពុជាអនុវត្តតាមបទដ្ឋានអប្បរមា របស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោសទៅតាមធនធានដែលមាន និងស្ថានភាពវិវឌ្ឍន៍ជាក់ស្តែងរបស់ ប្រទេសជាតិ ។

**៣**.ក្រសួងមហាផ្ទៃបានខិតខំរៀបចំច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធដល់ការងារគ្រប់គ្រងអ្នកទោស ឱ្យមានលក្ខណៈសមស្របតាមបទដ្ឋានជាតិ និងបទដ្ឋានអប្បរមារបស់អង្គការសហប្រជាជាតិ ។ ថ្មីៗកន្លងទៅនេះ ក្រសួងបានរៀបចំឱ្យមានរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចថ្មីរបស់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីរៀបចំ

កែ ទំរង់ប្រព័ន្ធពន្ធនាគារឱ្យមានភាពល្អប្រសើរតាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់បន្ថែមរបបអាហារ (ពី១.០០០រៀល ទៅ១.៥០០រៀល) និងសម្ភារៈប្រើប្រាស់ផ្សេងៗ ។ ការបណ្តុះបណ្តាលមន្ត្រីពន្ធនាគារ និងការបំពាក់ឧបករណ៍ការងារ ដើម្បីផ្តល់សេវាកែលំអសេវាសុខភាពអ្នកទោស កំពុងត្រូវបានដំណើរការបណ្តើៗយ៉ាងទៀងទាត់ និងបានបញ្ជ្រាបសេវា សុខភាពពន្ធនាគារជាបណ្តើរៗទៅក្នុងសេវាគ្របដណ្តប់របស់ក្រសួងសុខាភិបាល ដូចប្រជាពលរដ្ឋក្នុងសហគមន៏ដែរ។ បច្ចុប្បន្ន នេះ ប៉ុស្តិសុខភាពចំនួនបួនបានទទួលសេវាពេញលេញពីក្រសួងសុខាភិបាល ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃបាននឹងកំពុង សហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលនានារៀបចំនិងផ្តល់ជាបណ្តើរៗ នូវកម្មវិធីសំរាប់ស្តារ នីតិសម្បទាដល់អ្នកទោសនៅតាមពន្ធនាគារមួយចំនួន។

ក្រសួងមហាផ្ទៃបានបង្កលក្ខណៈងាយស្រួលដល់ការងារគ្រប់គ្រងពន្ធនាគារ ដោយបានលើកទឹកចិត្តឱ្យគ្រួសារ អ្នកទោសចូលមកសួរសុខទុក្ខតាមកាលវិភាគកំណត់ ព្រមទាំងខិតខំផ្តល់ឱកាសឱ្យអ្នកទោសកែប្រែខ្លួន ដើម្បីទទួលបាន ការបន្ធូរបន្ថយទោស ឬលើកលែងទោសតាមរយៈការវាយតំលៃចំណាត់ថ្នាក់សន្តិសុខ និងចូលរួមក្នុងកម្មវិធីរៀនសូត្រ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

៤.បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃបាននិងកំពុងដោះស្រាយបញ្ហាប្រឈមមួយចំនួន ដូចជាកសាង និងកែលំអ ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ ដែលមានភាពចាស់ទ្រុឌទ្រោមមិនអាចធានាដល់ការអនុវត្តប្រព័ន្ធគ្រប់គ្រង និងការងារអប់រំ កែប្រែ ។ យើងក៏កំពុងដោះស្រាយភាពចង្អៀតណែននៅតាមពន្ធនាគារ ដើម្បីសំរួលដល់លក្ខខ័ណ្ឌរស់នៅរបស់អ្នកទោស និងលើកកំពស់សមត្ថភាពនៃការផ្តល់សេវានៅតាមពន្ធនាគារឱ្យបានរិតតែសមស្រប ថ្វីត្បិតតែបច្ចុប្បន្ននេះ រាជរដ្ឋាភិបាល- កម្ពុជា កំពុងយកចិត្តទុកដាក់ដោះស្រាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលរយៈពេល ១០ឆ្នាំចុងក្រោយនេះ យើងបានកាត់បន្ថយពី ៤៧% មកនៅត្រឹម ៣៥ %។

ដូចនេះការលើកឡើងរបស់លោក ប្រេដ អាដាម ដែលឱ្យតំលៃការរស់នៅរបស់អ្នកទោសកម្ពុជា ដូចសត្វឆ្កែ គឺជាការប្រមាថមាក់ងាយយ៉ាងធ្ងន់ធ្ងរដល់ពិរុទ្ធជន និងទណ្ឌិត ដែលកំពុងខិតខំកែប្រែខ្លួនជាមនុស្សល្អ ហើយការប្រើពាក្យ សំដីបែបនេះ របស់លោក ប្រេដ អាដាម មិនសក្តិសមជាសកម្មជនសិទ្ធិមនុស្សឡើយ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០០៧*

***អ្នកនាំពាក្យក្រសួងមហាផ្ទៃ***